# មេរៀនទី៨៨៖ ដាវីឌយកឈ្នះលើកូលីយ៉ាត

## ១ សាំយូអែល ១៧៖១-៥០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/E-CQ4wEpz8s

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/w4NkSMp1mb0

**គោលបំណង៖** ព្រះអាចប្រើមនុស្សគ្រប់គ្នា។

**ខគម្ពីរចងចាំ៖ អេសាយ ៤០៖២៩** *"ទ្រង់រមែងចំរើនកំឡាំង ដល់អ្នកដែលល្វើយ ហើយចំណែកអ្នកដែលគ្មានកំឡាំងសោះ នោះទ្រង់ក៏ប្រទានឲ្យ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. យើងនឹងឈ្នះ https://youtu.be/Ba2UR8O5Rgw

២. ក្នុងព្រះនាមព្រះយេស៊ូវ https://youtu.be/0b41QksexPE

៣. ចូរមានកំម្លាងនិងមានចិត្តក្លាហាន https://youtu.be/Mr7oyUvG7U8

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ទាញព្រ័ត្រ»**

សម្ភារៈដែលត្រូវការ៖ ខ្សែពួ (ប្រើក្រម៉ាក៏បាន)



១. ចែកកុមារជា២ក្រុម ហើយគូសបន្ទាត់នៅចន្លោះកណ្ដាល

២. សូមឲ្យពួកគេលេងល្បែងទាញព្រ័ត្រ។ មេក្រុមណាដែលត្រូវគេអូសហួសបន្ទាត់នឹងចាញ់ល្បែងនេះ។

៣. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា មិនថាពួកគេមានមាឌធំប៉ុនណា វាមិនមានន័យថាពួកគេនឹងឈ្នះល្បែងនេះនោះឡើយ។ យើងមិនអាចមើលងាយនរណាម្នាក់ ដោយគ្រាន់តែឃើញមាឌរបស់គេនោះទេ។

**៤. ការណែនាំមេរៀន**

នៅពេលដែលអ្នកលេងបាល់ទាត់ តើអ្នកចង់បានក្រុមដែលមានសមាជិកខ្សោយ ឬខ្លាំង? ឬក៏នៅពេលដែលអ្នកឡើងភ្នំ តើអ្នកចង់ឡើងភ្នំជាមួយយុវជនដែលមានកំលាំងខ្សោយ ឬជាមួយមនុស្សចាស់ដែលមានកំលាំងខ្លាំង? លោកីយ៍នេះចង់បានមនុស្សធំ និងរឹងមាំ ប៉ុន្តែព្រះចង់បានមនុស្សដែលទុកចិត្តលើទ្រង់ ទោះជាគេតូច ទាប ឬខ្សោយក៏ដោយ។ ថ្ងៃនេះយើងនឹងរៀនពីវិធី ដែលព្រះបានប្រើក្មេងប្រុសជំទង់ម្នាក់ ដើម្បីប្រយុទ្ធជាមួយនឹងយក្ស។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

តើនរណាជាស្តេចរបស់អ៊ីស្រាអែល? សូលនៅតែជាស្តេចរបស់អ៊ីស្រាអែល។ ទោះជាហោរ៉ា សាំយូអែល បានចាក់ប្រេងតាំងដាវីឌជាស្តេចបន្ទាប់ពីសូលក៏ដោយ តែការនេះនឹងមិនអាចកើតឡើងទេ រហូតដល់ ដាវីឌ អាយុ៣០ឆ្នាំ។ ពេលនេះដាវីឌនៅជាក្មេងប្រុសនៅឡើយទេ។

នៅពេលនេះ អ៊ីស្រាអែលត្រូវបានឈ្លានពានដោយពួកភីលីស្ទីន។ ទាហានអ៊ីស្រាអែលប្រឈមមុខជាមួយ នឹងពួកភីលីស្ទីនរាល់ថ្ងៃ ហើយរងចាំឲ្យពួកភីលីស្ទីនវាយប្រហារមុន។ ប៉ុន្តែជំនួសឲ្យការវាយប្រហារលើ អ៊ីស្រាអែល ពួកភីលីស្ទីនបានបញ្ជូនកូលីយ៉ាតដែលមានកំពស់៦ហត្ថ១ចំអាម (ប្រហែល៣ម៉ែត្រ) មក ដើម្បីប្រមាថ តិះដៀលអ៊ីស្រាអែល និងព្រះ។ កូលីយ៉ាតបាននិយាយពាក្យប្រមាថរាល់ថ្ងៃប្រហែល ១ខែ ជាង ហើយឥតមានបុរសណាម្នាក់ក្នុងជួរកងទ័ពអ៊ីស្រាអែល ចេញមុខមកប្រយុទ្ធជាមួយនឹងកូលីយ៉ាត ទេ។ ដូច្នេះគាត់នៅតែបន្តធ្វើឲ្យជនជាតិអ៊ីស្រាអែលភ័យខ្លាច ហើយជនជាតិអ៊ីស្រាអែលនៅតែបន្តរត់ គេច។

នៅថ្ងៃមួយក្មេងប្រុសឃ្វាលចៀមដែលមានឈ្មោះថា ដាវីឌបានលឺថាកូលីយ៉ាតបានប្រមាថព្រះ គាត់ខឹង ខ្លាំងណាស់! ដេវីឌបានស្ម័គ្រចិត្តទៅប្រយុទ្ធជាមួយនឹងយក្សកូលីយ៉ាតនោះ ទោះជាគាត់គ្រាន់តែជាក្មេង ប្រុសក៏ដោយ។ គ្រប់គ្នាសើចចំអក ហើយបានប្រាប់ដាវីឌឲ្យទៅផ្ទះវិញ ប៉ុន្តែដាវីឌគាត់មានជំនឿចិត្ត ណាស់ ហើយគាត់ដឹងថាព្រះបានប្រើគាត់ឲ្យប្រយុទ្ធជាមួយនឹងតោ និងខ្លាឃ្មុំទាំងអស់នោះ ដើម្បីការពារ កូនចៀមតូចៗទាំងអស់។ ពិតណាស់ ដើម្បីការពារប្រជារាស្ត្ររបស់ទ្រង់ ព្រះនឹងជួយគាត់ប្រយុទ្ធជាមួយ នឹងយក្សកូលីយ៉ាត ដែលបានប្រមាថព្រះនោះ!

ស្តេចសូលបានព្យាយាមផ្តល់គ្រឿងសស្ត្រាវុធដល់ដាវីឌ ខណៈដែលកូលីយ៉ាតបានជេប្រមាថម្តងទៀត។ តែគ្រឿងសស្ត្រាវុធទាំងអស់នោះធំជាងដាវីឌ។ ជំនួសឲ្យការពឹងអាងដល់គ្រឿងសស្ត្រាវុធទាំងនោះ ដាវីឌ បានសំរេចចិត្តទុកចិត្តព្រះក្នុងការប្រើគាត់ដើម្បីប្រយុទ្ធជាមួយនឹងយក្ស។ ដាវីឌបានដើរទៅមាត់ជ្រោះ ហើយបានរើសដុំក្រួសមួយដៃ។ ដាវីឌបានដាក់ក្រួសមួយដុំក្នុងខ្សែដង្ហក់របស់ខ្លួន។ នេះជាអ្វីដែលគាត់ មាន។ ដាវីឌបានសំលាប់កូលីយ៉ាតដោយដុំគ្រួសនឹងខ្សែដង្ហក់របស់គាត់។

ដាវីឌមិនមានជំនឿចិត្តលើកំលាំងខ្លួនឯងទេ គាត់គ្រាន់តែជាក្មេងឃ្វាលចៀមម្នាក់ប៉ុណ្ណោះ។ គាត់មិនមែន ជាទាហ៊ាន ហើយគាត់មិនខ្លាំងទេ ប៉ុន្តែគាត់មានជំនឿចិត្តលើព្រះ។ កូលីយ៉ាតមានជំនឿចិត្តលើកំលាំង ខ្លួនឯង ហើយកូលីយ៉ាតបានធ្វើឲ្យខ្លួនឯង និងកងទ័ពរបស់គាត់ទាំងមូលបានដួលរលំ។ ដាវីឌជាភាគី ដែលទន់ខ្សោយជាងគេបើប្រៀបធៀបទៅនឹងបុរសខ្លាំងៗជាច្រើននៅក្នុងជួរកងទ័ពអ៊ីស្រាអែល ព្រះអាច នឹងប្រើបុរសខ្លាំងៗទាំងអស់នោះបាន ប៉ុន្តែព្រះបានប្រើដាវីឌជំនួសវិញ ពីព្រោះដាវីឌទុកចិត្តលើកំលាំង របស់ព្រះ។

ទោះជាពេលនេះអ្នកមើលទៅតូច តែព្រះអាចនៅតែប្រើអ្នកបាន។ តើអ្នកទុកចិត្តលើអំណាច នៃព្រះជំនួស ឲ្យកាទុកចិត្តលើកំលាំងរបស់ខ្លួនអ្នកដែរឬទេ? ព្រះប្រើក្មេងឃ្វាលចៀមម្នាក់បាន ព្រះក៏ ប្រាកដជាអាចប្រើ អ្នកឲ្យធ្វើការអស្ចារ្យសំរាប់ពិភពលោកនេះបានដែរ!

## ៦. សំនួរពិភាក្សា

១. តើនរណាជាស្តេចលើសាសន៍អ៊ីស្រាអែល? *(ស្តេចសូល)*

២. តើយក្សភីលីស្ទីនដែលប្រមាថអ៊ីស្រាអែល និងប្រមាថព្រះឈ្មោះអ្វី? *(កូលីយ៉ាត)*

៣. ហេតុអ្វីបានជាទាហានអ៊ីស្រាអែលខ្លាចក្នុងការប្រយុទ្ធជាមួយនឹងកូលីយ៉ាត? *(ព្រោះគាត់ជាយក្ស)*

៤. ហេតុអ្វីបានជាដាវីឌស្ម័គ្រចិត្តប្រយុទ្ធជាមួយកូលីយ៉ាត? *(គាត់ខឹងខ្លាំងដោយបានឮយក្សប្រមាថព្រះ)*

៥. តើដាវីឌសម្លាប់កូលីយ៉ាតដោយរបៀបណា? *(ជាមួយក្រួស និងខ្សែដង្ហក់)*

៦. តើអ្នកគិតថាព្រះអាចប្រើអ្នកបានដោយរបៀបណា បើអ្នកកម្លាំងខ្សោយ ហើយនៅតូចនៅឡើយដូច្នេះ? *(បង្ហាញសេចក្ដីស្រឡាញ់របស់ព្រះដល់អ្នកដទៃ ជួយគ្រួសារ ធ្វើជាគ្រីស្ទានគំរូដល់អ្នក ដទៃ។ល។)*

## ៧. ល្បែងកំសាន្ត «ដណ្ដើមស្លឹកឈើ»

សម្ភារៈដែលត្រូវការ៖ មែកឈើតូចល្មម



១. ចែកកុមារជា ២ក្រុម

២. ដាក់មែកឈើនៅចំកណ្ដាល ដោយឲ្យកុមារឈរទល់មុខគ្នា

៣. គ្រូត្រូវដាក់លេខរៀងឲ្យគូរនីមួយៗ

៤. នៅពេលដែលគ្រូហៅលេខ កុមារដែលលឺលេខរបស់ខ្លួន ពួកគេត្រូវរត់ឲ្យលឿនមកកន្លែងដាក់មែកឈើ។ ពួកគេត្រូវដណ្ដើមមែកឈើនោះទៅកាន់កន្លែងដើមវិញ ដោយមិនត្រូវឲ្យកុមារដែលមកពីក្រុមម្ខាងទៀតប៉ះគេបាននោះទេ។

៥. ឧទាហរណ៍៖ ប្រសិនបើគ្រូហៅ "គូរទី៣!" នោះអ្នកដែលមានលេខរៀងទី៣ ត្រូវរត់មកដណ្ដើមមែកឈើនោះ ហើយរត់ត្រឡប់ទៅកាន់ក្រុមគេវិញឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។

៦. ប្រសិនបើក្រុមម្ខាងទៀតប៉ះគេបាននោះគេនឹងចាញ់ល្បែងនេះ។

៧. បន្តលេងល្បែងនេះ រហូតដល់កុមារទាំងអស់បានលេងគ្រប់គូរ។

៨. ក្រុមណាដែលទទួលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៩. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ក្រុមដែលឈ្នះល្បែងនេះគឺមិនអាស្រ័យទៅលើមាឌ និងកម្លាំងនោះទេ។ សូមចាំថាព្រះអាចប្រើនរណាម្នាក់ក៏បាន ទោះបីជាអ្នកមានតូច ធំ ខ្សោយ ខ្លាំង ប្រុស ស្រី និងផ្សេងៗទៀត។ ព្រះអាចប្រើមនុស្សគ្រប់គ្នា រួមទាំងអ្នកផងដែរ!

## ៨. ខគម្ពីរចងចាំ

**អេសាយ ៤០៖២៩** *"ទ្រង់រមែងចំរើនកំឡាំង ដល់អ្នកដែលល្វើយ ហើយចំណែកអ្នកដែលគ្មានកំឡាំងសោះ នោះទ្រង់ក៏ប្រទានឲ្យ។"*

## ៩. ហត្ថកម្ម៖ «ព្រះអាចប្រើខ្ញុំបាន» - ចៀម

**សំភារៈដែលត្រូវការ៖** បោះពុម្ពក្រដាសរូបចៀម កន្ត្រៃ ការបិត




១. ឲ្យកុមារដានដៃរបស់ពួកគេនៅលើក្រដាសរូបចៀម ហើយកាត់រូបដៃនោះចេញ។

២. ឲ្យកុមារកាត់រូបចៀមនោះ ហើយបិតនៅលើរូបដៃហើយ ធ្វើយ៉ាងណាឲ្យឃើញរូបដៃ ដូចជាជើងរបស់ចៀម។




៣. ឲ្យកុមារកាត់ពាក្យថា "ព្រះបានប្រើក្មេងឃ្វាលចៀម ព្រះក៏អាចប្រើខ្ញុំដែរ!" ហើយយកវាទៅបិតនៅលើសត្វចៀម។

៤. ឲ្យកុមារទាំងអស់និយាយថា "ព្រះបានប្រើក្មេងឃ្វាលចៀម ព្រះក៏អាចប្រើខ្ញុំដែរ!"

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
មិនថាយើងជានរណាទេ ពេលដែលព្រះយេស៊ូវជាមិត្តសម្លាញ់ ហើយយើងបានថ្វាយជីវិតយើងដើរតាមព្រះអង្គហើយ ព្រះអង្គអាចធ្វើការដែលគួរឲ្យរំភើបតាមរយៈយើងបាន។ ដាវីឌមិនមែនជាអ្នកចម្បាំងដ៏អស្ចារ្យដែលបានសំលាប់យក្សកូលីយ៉ាតទេ តែដាវីឌជាក្មេងឃ្វាលចៀមធម្មតាម្នាក់។ តើនៅពេលណាដែលអ្នកបានធ្វើអ្វីមួយថ្វាយព្រះ ហើយអ្នកមានអារម្មណ៍ថាអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើវា? តើព្រះបានឆ្លើយតបដោយរបៀបណា? តើការដ៏អស្ចារ្យអ្វីខ្លះដែលព្រះអាចនឹងរងចាំធ្វើតាមរយៈអ្នក? អរគុណដល់ព្រះចំពោះឱកាស ដែលព្រះបានប្រទានឲ្យដល់អ្នកដើម្បីធ្វើការអស្ចារ្យសំរាប់ទ្រង់ និងតាមរយៈទ្រង់។

# ព្រះអាចប្រើខ្ញុំបាន!



## ព្រះបានប្រើក្មេងឃ្វាលចៀម។
## ព្រះក៏អាចប្រើខ្ញុំដែរ!

----------------------------------------------------------------------------------------------------------------

សូមគូរដានដៃរបស់អ្នកនៅខាងក្រោម: